# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ០១ ខែ មិនា ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ៩១,៤២៩ ដុល្លារអាមេរិក សម្រាប់គម្រោងបំពាក់ឧបករណ៍ពិនិត្យ និងព្យាបាលប្រព័ន្ធសោតវិញ្ញាណ



ក្រោមគ្រោងការណ៍ នៃ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច របស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ៩១,៤២៩ ដុល្លាអាមេរិក ដល់ អង្គការសុខភាពត្រចៀកនៅកម្ពុជា សម្រាប់ គម្រោង បំពាក់ឧបករណ៍ ពិនិត្យ និង ព្យាបាលប្រព័ន្ធសោតវិញ្ញាណនៅរាជធានីភ្នំពេញ។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខាថ្ងៃនេះ ដោយ លោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ ភារៈធារីស្តីទីស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកវេជ្ជបណ្ឌិតGlyn Vaughan ប្រធានអង្គការសុខភាពត្រចៀកនៅកម្ពុជា នៅស្ថានទូតជប៉ុន។



អង្គការសុខភាពត្រចៀកនៅកម្ពុជានឹងតំឡើងឧបករណ៍ពិនិត្យ និង ព្យាបាលប្រព័ន្ធសោតវិញ្ញាណដែលរួមមានឧបករណ៍បញ្ចាំងភ្លើងហ្វា និង បន្ទប់ធ្វើតេស្តការស្តាប់សម្លេងនៅគ្លីនិករបស់អង្គការក្នុងរាជធានីភ្នំពេញ ដើម្បីបង្កើនការផ្តល់សេវាដល់អ្នកជំងឺ។ យើងរំពឹងថាប្រជាជនប្រមាណ២,០០០នាក់ដែលមានបញ្ហាផ្នែកការស្តាប់ នឹង ទទួលបានអត្ថប្រយោជន៍ ពីការកែលម្អសេវាសុខភាពត្រចៀក ដែលផ្តល់ដោយ គ្លីនិក របស់ អង្គការនេះក្នុងរាជធានីភ្នំពេញ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង ភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និង សេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៤៨.៩ លានដុល្លាអាមេរិក ដល់ អាជ្ញាធរមូលដ្ឋាន និង អង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៨៨គម្រោងនៅទូទាំងប្រទេស។



---


ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp